**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៧-១៣៣ ប្រក

លិខិតចូល
ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ2007

## ប្រកាស
## ស្តីពី
## អនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខធ៧-០០-០៦ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខធ៧.០៧-១៣២ ប្រក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៧

### សំរេច

**ប្រការ ១.-**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលតទៅនេះហៅថាគ្រឹះស្ថាន ត្រូវពិនិត្យជាអចិន្ត្រៃយ៍នូវអនុបាតសាធនភាពរបស់ខ្លួនឱ្យបានស្របតាមបញ្ញត្តិនៃប្រកាសនេះ ។ អនុបាតសាធនភាពរវាងមូលនិធិផ្ទាល់សុទ្ធនិងហានិភ័យទ្រព្យសកម្មសរុប ដែលបានថ្លឹងមិនត្រូវតិចជាងដប់ប្រាំភាគរយ (១៥%) ឡើយ។

**ប្រការ ២.-**

ភាគយកនៃអនុបាត គឺជាមូលនិធិផ្ទាល់សុទ្ធដែលត្រូវបានគណនាស្របតាមបញ្ញត្តិនៃប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

**ប្រការ ៣.-**

**ក-** ភាគបែងនៃអនុបាត គឺជាតំលៃទ្រព្យសកម្មសរុប (តំលៃសុទ្ធក្រោយពេលដកចេញនូវសំវិធានធននិងការរំលោះតំលៃ) និងខ្ទង់ក្រៅតារាងតុល្យការដែលត្រូវបានថ្លឹងតាមកំរិតហានិភ័យ ។ ភាគបែងនេះមិនរាប់បញ្ចូលនូវខ្ទង់ដែលបានដកចេញនៅពេលគណនាមូលនិធិផ្ទាល់សុទ្ធ ស្របតាមបញ្ញត្តិនៃប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

**ខ-** ការថ្លឹងដូចខាងក្រោមនេះ នឹងអនុវត្តចំពោះទ្រព្យសកម្ម ÷

**ខ.១-** ការថ្លឹងសូន្យភាគរយ (zero weighting) ចំពោះ ÷

- សាច់ប្រាក់
- មាស
- ឥណទេយ្យលើធនាគារជាតិនៃកម្ពុជា
- ទ្រព្យសកម្មដែលមានវត្ថុបញ្ចាំជាប្រាក់បញ្ញើនៅធនាគារ
- ឥណទេយ្យលើ ឬធានាដោយស្ថាប័នអធិបតេយ្យ (Claims on sovereigns) ដែលមានចំណាត់ថ្នាក់ពីAAA ទៅ AA- ឬ ចំណាត់ថ្នាក់សមមូលតាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ។

**ខ.២-** ការថ្លឹង ២០% ចំពោះ ÷

- ឥណទេយ្យលើ ឬធានាដោយស្ថាប័នអធិបតេយ្យ ដែលមានចំណាត់ថ្នាក់ពី A+ ទៅ A- ឬចំណាត់ថ្នាក់សមមូល តាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា
- ឥណទេយ្យលើ ឬធានាដោយធនាគារ ឬក្រុមហ៊ុន ដែលមានចំណាត់ថ្នាក់ពី AAA ទៅ AA- ឬចំណាត់ថ្នាក់សមមូល តាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ។

**ខ.៣-** ការថ្លឹង ៥០% ចំពោះ ÷

- ឥណទេយ្យលើ ឬធានាដោយស្ថាប័នអធិបតេយ្យ ដែលមានចំណាត់ថ្នាក់ពី BBB+ ទៅ BBB- ឬចំណាត់ថ្នាក់សមមូល តាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ។
- ឥណទេយ្យលើ ឬធានាដោយធនាគារ ឬក្រុមហ៊ុន ដែលមានចំណាត់ថ្នាក់ពី A+ ទៅ A- ឬចំណាត់ថ្នាក់សមមូល តាមវិធីសាស្ត្ររបស់ភ្នាក់ងារចាត់ថ្នាក់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ។

ខ.៤. ការថ្លឹង ១០០% ចំពោះ ÷

- ទ្រព្យសកម្មដទៃទៀតទាំងអស់
- ខ្ទង់ក្រៅតារាងតុល្យការទាំងអស់ ។

**ប្រការ ៤.-**

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៥.-**

ប្រការ១៥ នៃប្រកាសលេខធ៧-០០-០៦ប្រក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងរាល់លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៧.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ សីហា ឆ្នាំ២០០៧

**ទេសាភិបាល**

**កន្លែងទទួល**

- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7.07.133 Prokor

Unofficial Translation

# PRAKAS
# on
# Microfinance Institutions' Solvency Ratio

**The Governor of the National Bank of Cambodia**

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996, promulgating the Law on the Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999, promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/RKT/0904/244 of September 7, 2004, on the appointment of His Excellency **Chea Chanto** as Governor General of the National Bank of Cambodia, equivalent to Senior Minister;
- With reference to the Prakas No B7-00-06 dated January 11, 2000, on the Licensing of Micro-Financing Institutions;
- With reference to the Prakas No B7-07-132 dated August 27, 2007, on the calculation of Microfinance Institutions' Net Worth;
- Pursuant to the recommendation made by National Bank of Cambodia management during the August 15, 2007, meeting.

## DECIDES

**Article 1**

Microfinance Institutions, hereafter referred to as "institutions", shall at all times observe a solvency ratio in accordance with the provisions of this Prakas. This solvency ratio of their net worth to their aggregate asset risk exposure shall not be less than 15 percent.

**Article 2**

The numerator of the ratio shall be the net worth calculated in accordance with the provisions of the Prakas on the calculation of microfinance institutions' net worth.

**Article 3**

3.1- The denominator of the ratio shall comprise the aggregate of the assets (net amount after deduction of provision and depreciation) and off-balance sheet items, weighted to their degree of risk. It excludes the items which are deducted in calculating the net worth according to the provisions of the Prakas on the calculation of microfinance institutions' net worth.

3.2- The following weightings shall apply to assets:

3.2.1- zero weighting:

- cash,
- gold,
- claims on the National Bank of Cambodia,
- assets collateralized by deposits lodged with the bank,
- claims on or guaranteed by sovereigns rated AAA to AA- or equivalent rated under the methodology used by a rating agency acknowledged by the National Bank of Cambodia.

3.2.2- 20 percent weighting:

- claims on or guaranteed by sovereigns rated A+ to A- or equivalent rated under the methodology used by a rating agency acknowledged by the National Bank of Cambodia.
- claims on or guaranteed by banks or corporations rated AAA to AA- or equivalent rated under the methodology used by a rating agency acknowledged by the National Bank of Cambodia.

3.2.3- 50 percent weighting:

- claims on or guaranteed by sovereigns rated BBB+ to BBB- or equivalent rated under the methodology used by a rating agency acknowledged by the National Bank of Cambodia.
- claims on or guaranteed by banks or corporations rated A+ to A- or equivalent rated under the methodology used by a rating agency acknowledged by the National Bank of Cambodia.

3.2.4- 100 percent weighting:

- All other assets.
- All off-balance sheet items.

**Article 4**

Banks and Financial Institutions that are not compliant with this Prakas will be penalized according to Article 52 of the Law on Banking and Financial Institutions.

**Article 5**

Article 15 in Prakas No B7-00-06 dated January 11, 2000, on the Licensing of Microfinance Institutions and all provisions contrary to those of this Prakas are hereby repealed.

**Article 6**

The General Director, the General Secretariat, the General Inspection, the General Cashier, all Departments of the National Bank of Cambodia, and all Banks and Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article 7**

This Prakas shall take effect from this signing date.

Phnom Penh, August 27, 2007

**The Governor**

**Signed and Sealed**

cc:
- All members of the Board of Directors
- The parties concerned as stated in Article 6
- File
- CM "for info"
- Administration Department of CM
  "for publication in the National Gazette"